# តើការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទនឹងកើតឡើងនៅពេលណា ?

សៀវភៅសិក្សាព្រះគម្ពីរសញ្ញាថ្មីសម្រាប់ថ្នាក់សិក្ខាសាលា

តើអ្នកធ្លាប់ឆ្ងល់ទេថា តើពេលណាដែលការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទនឹងកើតឡើង ឬថាតើអ្នកនឹងត្រៀមខ្លួនដែរឬទេ ? ពួកបរិសុទ្ធនៅថែស្សាឡូនីចទំនងជាមានសំណួរដូចគ្នានេះ ។

សូមអាន ថែស្សាឡូនីច ទី១ ៥:១–៣ ហើយរកមើលពាក្យប្រៀបធៀបដែលប៉ុលបានប្រើដើម្បីពិពណ៌នាអំពីពេលវេលាដែលព្រះយេស៊ូវនឹងយាងមកផែនដីវិញ ។

- តើអ្នកបានរកឃើញអ្វីខ្លះ ?

- តើពាក្យប្រៀបធៀបរបស់ប៉ុលអំពីចោរនៅពេលយប់ និងស្ត្រីកំពុងសម្រាលកូនបង្រៀនអ្នកអ្វីខ្លះអំពីការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ?

សូមអាន ថែស្សាឡូនីច ទី១ ៥:៤–៦ ហើយរកមើល សេចក្ដីពិតដែលប៉ុលបានបង្រៀនអំពីការត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ។ សូមប្រៀបធៀបការបង្រៀនទាំងនេះជាមួយ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦:៤–៥ ។

- តើអ្នកទទួលបានការយល់ដឹងអ្វីខ្លះ ?

សេចក្ដីពិតមួយដែលយើងអាចរៀនចេញពីការបង្រៀនរបស់ប៉ុលគឺថា **ប្រសិនបើយើងខិតខំធ្វើជា « កូនចៅនៃពន្លឺ » ដោយការធ្វើតាមព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងត្រូវបានត្រៀមខ្លួនរួចនៅពេលទ្រង់យាងមកម្ដងទៀត** ។

ដើម្បីរៀនបន្ថែមទៀតអំពីវិធីផ្សេងៗ ដែលព្រះអម្ចាស់អញ្ជើញយើងឲ្យក្លាយជាកូនចៅនៃពន្លឺ សូមអាន នីហ្វៃ ទី៣ ១៨:២៤; គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:២៣–២៥; ៨៨:៦៧–៦៨ ។ សូមធ្វើបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សារបស់អ្នក នូវអ្វីដែលអ្នករកឃើញ ដែលជួយអ្នកឲ្យយល់ពីរបៀបក្លាយជាកូនចៅនៃពន្លឺ ។

- តើអ្នកអញ្ជើញពន្លឺរបស់ព្រះអម្ចាស់មកក្នុងជីវិតអ្នកដោយរបៀបណា ? តើអ្នកអាចអញ្ជើញពន្លឺរបស់ទ្រង់បន្ថែមទៀតមកក្នុងជីវិតអ្នកដោយរបៀបណា ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ឆ្នាំ ២០២២ by Intellectual Reserve, Inc. All rights reserved. កំណែ ៖ ២/២១ ។ ការបកប្រែនៃ *When Will the Second Coming of Jesus Christ Happen?*
Cambodian. PD60012661 258. Printed in the United States of America.